USAID
FROM THE AMERICAN PEOPLE

WINROCK INTERNATIONAL
Putting Ideas to Work



គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ ( CTIP II )

ចេញផ្សាយលេខ ៤ ខែកក្កដា - កញ្ញា ឆ្នាំ២០១៤

## ចេញពីការធ្លាក់ខ្លួនយ៉ាងវេទនា ទៅកាន់ជីវិតពោរពេញដោយក្តីសង្ឃឹម

ម.ស. ជាកុមារីអាយុ១៥ឆ្នាំ បានបោះបង់សាលាតាំងពីវ័យក្មេង ដើម្បីធ្វើចំណាកស្រុកទៅភ្នំពេញ តាមឪពុកម្តាយរបស់នាង ក្នុងការស្វែងរកការងារធ្វើ។ ទោះបីជាការងារលំបាកធ្ងន់ធ្ងរប៉ុណ្ណា ក៏មិនទាស់ខុសអ្វីដែរសម្រាប់ពួកគេ គឺពួកគេត្រូវតែធ្វើដើម្បីរស់។

ថ្ងៃមួយ ម.ស. ត្រូវបានអ្នកជិតខាងល្បួងលួងលោមបោកបញ្ឆោតឲ្យធ្វើជាស្រីពេស្យា។ សំណាងល្អ មួយរយៈក្រោយមកនាងបានគេចខ្លួនរួច ហើយមករស់នៅជាមួយឪពុកម្តាយនាងវិញ មិនតែប៉ុណ្ណោះ នាងក៏មានសេចក្តីក្លាហាន ដោយបានប្តឹងទៅកាន់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន (AHTJP) ដែលឈានដល់ការឃាត់ខ្លួនមេអណ្តើកដែលបញ្ចុះបញ្ចូលបោក បញ្ឆោតរូបនាង។

នៅពេលដែលកំពុងរង់ចាំយុត្តិធម៌ អង្គការដៃគូរបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស CTIP II គឺមជ្ឈមណ្ឌលជួយស្ត្រីកម្ពុជាមានវិបត្តិ (CWCC) បានផ្តល់ប្រឹក្សាផ្នែកផ្លូវចិត្ត និងផ្តល់ឱកាសឲ្យនាងបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញកែសម្ផស្ស។ ក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាល នាងក៏បានទទួលជំនួយថវិកាពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់អភិវឌ្ឍអន្តរជាតិ USAID ដែលអាចឲ្យនាង ចាប់ផ្តើមដំណើរការហាងកែសម្ផស្សមួយដោយខ្លួនឯងបាន។

"ខ្ញុំសប្បាយរីករាយខ្លាំងណាស់ដែលគម្រោងប្រឆាំងអំពើជួញដូរមនុស្ស CTIP II តែជួយគាំទ្រខ្ញុំ" ម.ស.និយាយ។

នាងបានអរគុណចំពោះហាងកែសម្ផស្សរបស់នាង ដែលសព្វថ្ងៃនាងរកប្រាក់បានប្រហែល ២០.០០០ រៀល (៥ដុល្លារអាមេរិក) ក្នុងមួយថ្ងៃ។ បច្ចុប្បន្ន នាងប្រាថ្នារៀនភាសាអង់គ្លេស និងពង្រីកហាងកែសម្ផស្សរបស់នាង ដោយនាងប្រាប់ពួកយើងថា នាងចង់បណ្តុះបណ្តាលប្អូនប្រុសរបស់នាងឲ្យចេះជំនាញ កាត់សក់ដើម្បីរំដោះជីវិតពួកគេចេញពីមុខរបរគ្រោះថ្នាក់។



## សង្ខេបទិន្នន័យខ្លះរបស់គម្រោងប្រឆាំងអំពើជួញដូរមនុស្ស CTIP II (ឆ្នាំ២០១១-២០១៥)

**ចំនួនអ្នករួចពីគ្រោះថ្នាក់/ជនរងគ្រោះដែលបានជួយឧបត្ថម្ភគាំទ្រ**

- ៥៧៩ នាក់រួចពីគ្រោះថ្នាក់នៃការជួញដូរពលកម្ម
- ៥២ នាក់រួចពីគ្រោះថ្នាក់នៃការជួញដូរផ្លូវភេទ
- ១៣៥ នាក់រួចពីគ្រោះថ្នាក់នៃការកេងប្រវ័ញ្ចពលកម្មប្រភេទសេវា និងជំនួយដែលបានផ្តល់
- ៤១៩ នាក់ដែលបានរំដោះត្រូវបានបញ្ជូនត្រឡប់ទៅស្រុកវិញ៤១៩
- ៤៨១ នាក់ដែលបានរំដោះបានទទួលការប្រឹក្សាផ្នែកផ្លូវចិត្ត
- ៣៨៣ នាក់ដែលបានរំដោះបានទទួលការប្រឹក្សាយោបល់ផ្នែកច្បាប់
- ៧៨ នាក់ដែលបានរំដោះត្រូវបានជួយប្តឹងប្រឆាំងនឹងអ្នកប្រព្រឹត្តបទឧក្រិដ្ឋ
- ៣៨ នាក់ដែលបានរំដោះបានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងរបរចិញ្ចឹមជីវិត
- ១៧៦ នាក់ដែលបានរំដោះត្រូវបានធ្វើសមាហរណកម្ម
- ៧៤ នាក់ដែលបានរំដោះត្រូវបានផ្តល់ទុនបង្កើតមុខរបរ និងប្រាក់ជំនួយចាប់ផ្តើមជីវិតឡើងវិញ

* តួលេខដែលបានធ្វើបច្ចុប្បន្នភាពត្រឹមថ្ងៃទី៣០ មីនា ២០១៤ និងតួលេខដែលបានធ្វើបច្ចុប្បន្នភាពត្រឹមថ្ងៃទី៣០ ធ្នូ ២០១៣។

## រដូវភ្លៀង៖ រដូវកាលថតខ្សែវីដេអូ សម្រាប់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ (CTIP II)

ថ្មីៗនេះ គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដំណាក់កាលទី២ (CTIP II) បានផលិតខ្សែវីដេអូ ស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដែលនិយាយអំពីការសាកសួរព័តមានឲ្យច្បាស់លាស់ មុនពេលធ្វើការសម្រេចចិត្តរបសពលករ ២នាក់នៅក្នុងប្រទេសកម្ពុជា ដែលទីបញ្ចប់ ពួកគាត់អាច ចំណាក ស្រុកទៅកាន់ប្រទេសគោលដៅ។

ការផលិតខ្សែវីដេអូនេះ គឺបានឆ្លើយតបនឹងតម្រូវការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) ដែលបានរួមគ្នាជាមួយអង្គការមិនមែន រដ្ឋាភិបាលមួយចំនួនដែលធ្វើការក្នុងវិស័យនេះ បានផ្តល់គំនិតយោបល់យ៉ាងសំខាន់ក្នុងការផលិតខ្សែវីដេអូនេះ។ ជាពិសេស ខ្សែវីដេអូនេះត្រូវបានបង្កើតឡើងទាន់ពេលវេលា ពីព្រោះនៅពេលថ្មីៗនេះ ក្រសួង និងអង្គការពលកម្មអន្តរជាតិ (ILO) បានលើកឡើងពីកង្វះខាតសម្ភារដើម្បីគាំទ្រប្រកាសដែល បានដាក់ចេញកាលពីខែធ្នូមុននេះ។



យើងសង្ឃឹមថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងផ្តល់ការអនុម័តលើខ្សែរឿងវីដេអូនេះ ហើយនឹងយកទៅផ្សព្វផ្សាយក្នុងពេលឆាប់រហ័ស។ គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស CTIP II ក៏បានផលិតវីដេអូពីររឿងទៀត កាលពីត្រីមាសមុន៖ រឿងទី១ គឺស្តីពីការផ្តល់ឱកាសឲ្យជនរងគ្រោះពីការជួញដូរមនុស្ស (VoT) ដើម្បីចែករំលែកអំពីការធ្វើសមាហរណកម្មប្រកបដោយជោគជ័យ និងអំពីការគាំទ្រដែលពួកគេបានទទួលពីគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស CTIP II និង រឿងទី២ គឺស្តីពីជនរងគ្រោះកម្ពុជា ដែលរងគ្រោះពីការជួញដូរមនុស្សទៅធ្វើការលើទូកនេសាទ។

ខ្សែវីដេអូចុងក្រោយនេះ គឺផ្តោតជាសំខាន់លើការកាត់ទោស និងការតស៊ូមតិដើម្បីឲ្យមានចំណាត់ការឲ្យកាន់តែខ្លាំងឡើង ជាពិសេសជំរុញឲ្យមានការកាត់ទោសចំពោះក្រុមហ៊ុន ដ្យាអិន អូសិន អ៊ីនធើណេសិនណល។ យើងសូម ថ្លែងអំណរគុណជាពិសេសចំពោះការគាំទ្រពីសំណាក់អង្គការដៃគូរបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស CTIP II ដែលមានមជ្ឈមណ្ឌលកម្ពុជាជួយស្ត្រីមានវិបត្តិ (CWCC) អង្គការគាំទ្រផ្នែកច្បាប់សំរាប់កុមារ និងស្ត្រី (LSCW) និងមជ្ឈមណ្ឌលកម្ពុជាសំរាប់ការពារសិទ្ធិកុមារ និងស្ត្រី (CCPCR) ។

## ករណីក្រុមហ៊ុន ដ្យាអិន អូសិន ទាមទារពេលវេលាដើម្បីស្វែងរកយុត្តិធម៌

កាលពីខែមេសា សាលាដំបូងរាជធានីភ្នំពេញ បានចេញសាលក្រមសម្រេចដាក់ទោសក្រុមហ៊ុន ដ្យាអិន អូសិន អ៊ិនធើណេសិនណលហ្វីសសឺរី គឺជាភ្នាក់ងារជ្រើសរើសពលករមួយ ដែលបានបញ្ជូនពលករកម្ពុជាប្រហែល ១.០០០នាក់ តាមការប៉ាន់ស្មាន តាមរូបភាពជួញដូរមនុស្ស ដោយបង្ខំង ឲ្យធ្វើការលើទូកនេសាទ នៅទូទាំងពិភពលោក។ មនុស្សប្រាំមួយនាក់ ត្រូវបានផ្តន្ទាទោសដោយកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន ១០ឆ្នាំ ហើយជនរងគ្រោះត្រូវតែទទួលបានសំណងជំងឺចិត្ត និងការខូចខាត។

ទោះបីជាយ៉ាងណា តាមប្រភពពីអង្គការគាំទ្រផ្នែកច្បាប់សំរាប់កុមារ និងស្ត្រី (LSCW) ដែលជាដៃគូរបស់គម្រោង បានឲ្យដឹងថាករណីជនសង្ស័យ លីនលី ចេន បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលដីកាសម្រេចរបស់សាលាដំបូង នៅដើមខែមិថុនា ដើម្បីព្យាយាមពន្យារពេលដំណើរការទូទាត់សំណង។ រហូតមកដល់ពេលនេះ មេធាវីអង្គការក្រៅរដ្ឋាភិបាល មិនទាន់បានទទួលឯកសារថតចំឡងសាលក្រមរបស់តុលាការ ដើម្បីយកមកផ្ទៀងផ្ទាត់ឈ្មោះជនរងគ្រោះ ក្រែងលោពួកគេមិនមានក្នុងបញ្ជីឈ្មោះដែលត្រូវទទួលសំណងជំងឺចិត្ត។ គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ (CTIP II) ដៃគូអង្គការគាំទ្រផ្នែកច្បាប់សំរាប់កុមារ និងស្ត្រី (LSCW) កំពុងធ្វើការលើករណីខាងលើនេះ នៅបណ្តឹងសាសាឧទ្ធរណ៍។ ពួកគេ ក៏បានបង្ហាញក្នុងកម្មវិធីវិទ្យុពិភាក្សាអំពីករណីក្រុមហ៊ុន ដ្យាអិន អូសិន ក្នុងខែ មិថុនា។



## គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ (CTIP II) បានចាប់ផ្តើមគម្រោងសាកល្បងមួយ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការប្រឆាំងអំពើជួញដូរមនុស្ស

ក្នុងខែមិថុនា គម្រោងប្រឆាំងអំពើជួញដូរមនុស្ស CTIP II បានសហការជាមួយអង្គការដៃគូមួយ គឺសមាគមន៍យុវជនខ្មែរ (KYA) ដើម្បីរួមគ្នាផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធសំខាន់ៗ មួយចំនួនក្នុងការបង្ការទប់ស្កាត់ការធ្វើចំណាកស្រុកប្រកបដោយគ្រោះថ្នាក់ និងការជួញដូរមនុស្ស ។ គម្រោងប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ (CTIP II) បានបញ្ជ្រាបការងារនេះតាមរយៈវគ្គបណ្តុះបណ្តាលនៅខេត្ត

ស្វាយរៀង ព្រៃវែង កំពង់ចាម សៀមរាប កោះកុង ដើម្បីណែនាំដល់សិក្ខាកាមពីទម្រង់ថ្មីនៃការចុះឈ្មោះអ្នកធ្វើចំណាកស្រុក។ ទម្រង់ថ្មីនេះអាចជួយកត់ត្រាតាមដានកាន់តែប្រសើរ ឡើងចំពោះករណីជួញដូរមនុស្ស (TIP) និងជួយឲ្យកាន់តែប្រសើរឡើងក្នុងការគ្រប់គ្រងលំហូរនៃការធ្វើចំណាកស្រុក។ ឃុំចំនួនប្រាំ បានស្ម័គ្រចិត្តចូលរួមអនុវត្តគម្រោងសាកល្បង និងហ្វឹកហាត់ដើម្បីចាប់ផ្តើមការងារនេះ។

គម្រោងប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ (CTIP II) ក៏បានបង្ហាញទម្រង់នេះដល់អង្គការមជ្ឈមណ្ឌលកម្ពុជាជួយស្ត្រី មានវិបត្តិ (CWCC) ក្នុងខេត្តបន្ទាយមានជ័យ ដែលពួកគេនឹងយកទៅណែនាំបន្តដល់ ឃុំនានាក្នុងខេត្ត។ ពួកគេនឹងជ្រើសរើសឃុំចំនួនប្រាំ ដើម្បីអនុវត្តគម្រោងសាកល្បងនេះផងដែរ។ យើងសូមជូនពរឲ្យពួកគេមានដំណើរការល្អ!



## ក្រុមជួយខ្លួនឯងនៃគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ (CTIP II) កំពុងធ្វើឲ្យប្រសើរឡើង នូវអនាគតជនរងគ្រោះពីការជួញដូរមនុស្ស

ខេត្តស្វាយរៀង ជាខេត្តជាប់ព្រំដែនវៀតណាម ដែលគួរឲ្យព្រួយបារម្ភថាមានគ្រួសារអស់សង្ឃឹមមួយចំនួនតែងនាំកូនចៅទៅសុំទានក្នុងប្រទេសវៀតណាម។ យើងពិបាកវាយតម្លៃពីទំហំនៃបាតុភូតនេះ ប៉ុន្តែបើយោងតាមអង្គការដៃគូ គឺមជ្ឈមណ្ឌលកម្ពុជាដើម្បីការពារកុមារ និងស្ត្រី (CCPCR) បានឲ្យដឹងថាចំនួនកុមារសុំទានតាមការប៉ាន់ស្មាន ប្រហែលជាលើសពីមួយរយនាក់។

ដើម្បីប្រឆាំងទប់ទល់នឹងបញ្ហានេះ គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ (CTIP II) ក្នុងកិច្ចសហការជាមួយអង្គការដៃគូរបស់ខ្លួន CCPCR បានចាប់ផ្តើមអនុវត្តគម្រោងក្រុមជួយខ្លួនឯងក្នុងតំបន់នៅខែកញ្ញា ឆ្នាំ២០១៣។ យុទ្ធសាស្ត្រក្រុមជួយខ្លួនឯង គឺដើម្បីបង្កើតការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពដល់គ្រួសារទាំងនោះ និងសម្រាប់អ្នកដែលងាយរងគ្រោះពីការជួញដូរ និងដើម្បីបង្កើតសំណាញ់សុវត្ថិភាពសង្គមក្នុងសហគមន៍។ ការគ្រប់គ្រងហិរញ្ញវត្ថុ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបង្កើតផែនការអាជីវកម្ម និងប្រាក់កម្ចី គឺជារឿងចាំបាច់ជាច្រើនដែលត្រូវធ្វើ ប៉ុន្តែយើងបានធ្វើត្រឹមតែមួយពីរប៉ុណ្ណោះក្នុងយុទ្ធសាស្ត្រនេះ។ ទស្សនៈវិស័យនៃក្រុមជួយខ្លួនឯងចំពោះប្រាក់កម្ចីគឺផ្តល់ឲ្យសមាជិកណាដែលត្រូវការយកទៅប្រើប្រាស់ហើយពួកគេនឹង



ត្រូវសងវិញជាដំណាក់ៗ ដោយបង់ការប្រាក់ប្រចាំខែប្រមាណ ៣ដុល្លារអាមេរិក ដែលកន្លងមកបាន និងកំពុងដំណើរការបណ្តើរៗហើយ។

លើសពីនេះ ក្រុមជួយខ្លួនឯង ក៏បានជួយលើកទឹកចិត្តក្រុមគ្រួសារទាំងឡាយ ដើម្បីជួយគាំទ្រដល់ការអប់រំកូនចៅរបស់ពួកគេ និងជូនដំណឹងដល់ពួកគេអំពីហានិភ័យ និងផលវិបាកទាំងឡាយដែលឲ្យកូនចៅទៅសុំទាន។ ពិតណាស់ដៃគូគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស CTI II គឺ CCPCR បានផ្តល់ការអប់រំដល់កុមារទាំងនោះក្នុងអំឡុងពេលនៃការស្នាក់នៅជាបណ្តោះអាសន្នក្នុងជំរករបស់ពួកគេផងដែរ។

បច្ចុប្បន្នមានក្រុមជួយខ្លួនឯងពីរ ដែលកំពុងផ្តល់អត្ថប្រយោជន៍ដល់សមាជិកចំនួន ៥៩នាក់។ ក្នុងខែឧសភាឆ្នាំ ២០១៤ សមាជិកក្រុមទី១នៃក្រុមជួយខ្លួនឯងបានរៀនអំពីរបៀបបង្កើតផែនការអាជីវកម្ម ហើយមួយខែក្រោយមក ពួកគេក៏បានទទួលទុនឧបត្ថម្ភចាប់ផ្តើម អាជីវកម្មពីមូលនិធិរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ ដែលចាប់តាំងពីពេលនោះមកពួកគេក៏បាន និងកំពុងដំណើរការអាជីវកម្មរបស់ពួកគេ។ រីឯក្រុមទី២វិញ បច្ចុប្បន្នកំពុងបង្កើតគម្រោងថ្មីមួយ ដែលបង្កលទ្ធភាពឲ្យសមាជិកក្រុមទាំងអស់យ៉ាងហោចណាស់ មានមេគោផ្ទាល់ខ្លួនមួយ។ គោលគំនិតនេះ គឺដំបូងផ្តល់ឱកាសឲ្យសមាជិកក្រុម១០នាក់ដែលបានជ្រើសរើស សម្រាប់ទទួលបានមេគោមុនគេដើម្បីយកកូនទី១ ហើយបន្ទាប់មកពួកគេត្រូវផ្តល់មេគោ ទាំងនោះបន្តឲ្យទៅសមាជិកផ្សេងៗទៀតក្នុងក្រុមជាបន្តបន្ទាប់ ដើម្បីចិញ្ចឹម យកកូនគោទី២ និងទី២ និងកូនបន្តបន្ទាប់ទៀត។ គោលការណ៍ពិសេស នេះត្រូវបានបង្កើតឡើងដោយសមាជិកក្រុមរបស់ពួកគេ ដែលជាសញ្ញាដ៏អស្ចារ្យមួយក្នុងការផ្លាស់ប្តូរគំនិតបញ្ញា និងការពង្រឹងសាមគ្គីភាព

**ព័ត៌មានសង្ខេបក្នុងត្រីមាសនេះ**

- ការបង្កើតផែនការសកម្មភាពជាតិ៖ ទាំងរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលបានចែករំលែកគំនិតយោបល់ដល់គណៈកម្មាធិការជាតិ។ គំនិតយោបល់ចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល គឺត្រូវបានទទួលអបអរសាទរ និងការគាំទ្រយ៉ាងពេញទំហឹងពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ MoLVT ។

# លេខទូរស័ព្ទសារជាសំឡេង ស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ០៩៥ ៩៧៥ ៨០៤

រាល់ការហៅពីប្រព័ន្ធ Cellcard (សែលកាត) នឹងមិនគិតថ្លៃទេ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤

## ប្រសិនបើអ្នកបានជួបប្រទះ ឬធ្លាក់ក្នុងអំពើជួញដូរមនុស្ស អ្នកអាចស្វែងរកជំនួយបានតាមរយៈ លេខទំនាក់ទំនងដូចខាងក្រោម

### ក្នុងប្រទេសកម្ពុជា

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
០២៣ ៩៩ ៧៩ ១៩ ឬ ១២៨៨ (ហៅចូលដោយឥតគិតថ្លៃ)

### ការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៅតាមបណ្តាខេត្ត ក្រុង

| | |
|---|---|
| ក្រុងភ្នំពេញ | ០១៧ ២៧៦ ២២២ |
| ខេត្តសៀមរាប | ០១៧ ២៥៨ ២២២ |
| ខេត្តបាត់ដំបង | ០១៧ ២៣៦ ២២២ |
| ខេត្តកំពង់ធំ | ០១៧ ២៥៤ ២២២ |
| ខេត្តបន្ទាយមានជ័យ | ០១៧ ២៦០ ២២២ |
| ខេត្តកំពង់ឆ្នាំង | ០១៧ ៣២៦ ២២២ |
| ក្រុងព្រះសីហនុ | ០១៧ ២៥៩ ២២២ |

### លេខទំនាក់ទំនងអង្គការនៅក្នុងប្រទេសកម្ពុជា

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)
០៩៨ ៣៦០ ០៤៩ (ប៉ោយប៉ែត)
០៨៨ ៦៩៥ ៤១៧៨ (សៀមរាប)

អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW)
០៧៧ ៤៥៥ ៥១៦

អង្គការមជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR)
០១២ ៩១៣ ១៣៨

### លេខទំនាក់ទំនងនៅក្រៅប្រទេស

ស្ថានទូតកម្ពុជា នៅប្រទេសថៃ
+៦៦ ២៩ ៥៧៥ ៨៥១

អង្គការសម្ព័ន្ធសកលប្រឆាំងអំពើជួញដូរស្ត្រី នៅប្រទេសថៃ (GAATW)
+៦៦ ២៨ ៦៤១ ៤២៧

អង្គការ LPN នៅប្រទេសថៃ
+៦៦ ៣៤ ៤៣៤ ២៦៧

ស្ថានទូតកម្ពុជា នៅប្រទេសម៉ាឡេស៊ី
+៦០ ៣៤ ២៥៧ ១១៥០
+៦០ ៣៤ ២៥៧ ៣៧១១

អង្គការទីណាហ្គានីតា នៅប្រទេសម៉ាឡេស៊ី
+៦០ ៣៧ ៧៧០ ៣៦៩១

ក្រសួងការងារ នៅប្រទេសសិង្ហបុរី (MOM)
+៦៥ ៦៤ ៣៨៥ ១២២ (សម្រាប់សំណួរទូទៅ)
+៦៥ ៦៥ ៣៨៦ ៩៣០ (សំណួរទាក់ទងនឹងគុណភាពសេវាកម្ម)

ភ្នាក់ងារពឹងពាក់សម្រាប់អ្នកបម្រើដែលស្នាក់នៅបណ្តោះអាសន្ន នៅប្រទេសសិង្ហបុរី (TWC2)
+៦៥ ៦២ ៤៧៧ ០០១

អង្គការមនុស្សធម៌សម្រាប់សេដ្ឋកិច្ចនៃការធ្វើទេសន្តប្រវេសន៍ នៅប្រទេសសិង្ហបុរី (HOME)
បណ្តាញជំនួយ២៤ម៉ោងសម្រាប់ស្ត្រី និងបុរស បំរើការងារតាមផ្ទះ:
+៦៥ ៦៣ ៤១៥ ៥២៥ (សម្រាប់ស្ត្រី)
+៦៥ ៦៣ ៤១៥ ៥៣៥ (សម្រាប់បុរស)

អង្គការវីនរ៉ក់អន្តរជាតិ ជាអង្គការមិនរកផលចំណេញ ដែលធ្វើការជាមួយប្រជាជនក្នុងសហរដ្ឋអាមេរិក និង នៅទូទាំងពិភពលោក ដើម្បីជួយដល់ជនក្រីក្រ បង្កើនឱកាសរកប្រាក់ចំណូល និងថែរក្សាធនធានធម្មជាតិអោយបានគង់វង្ស។

ការិយាល័យអង្គការវីនរ៉ក់នៅប្រទេសកម្ពុជា
WINROCK INTERNATIONAL
Putting Ideas to Work
មជ្ឈមណ្ឌលភ្នំពេញ អគារ អែហ្វ បន្ទប់លេខ ៧៨៧ មហាវិថី សុធារស រាជធានីភ្នំពេញ ទូរស័ព្ទ: +៨៥៥-២៣ ២១២ ៣៣៤/៦ ទូរសារ: +៨៥៥-២៣ ២១២ ៣៣៥
សារអេឡិចត្រូនិច: cambodiaadmin@field.winrock.org
គេហទំព័រ: www.winrock.org